ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : មស.

លិខិតជូនពរ

សូមគោរពជូន
ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២២ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យ សិរីសួស្តី បវរមហាប្រសើរជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត និងលោកជំទាវ**។

ក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លានេះដែរ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវមនោសញ្ចេតនាគោរពនិងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ក្នុងបេសកកម្មដឹកនាំស្ថាប័នទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបុព្វហេតុបម្រើជាតិមាតុភូមិកម្ពុជា ជាមួយរាជរដ្ឋាភិបាល សំដៅចូលរួមជាឧត្តមប្រយោជន៍ជាតិនិងប្រជាជននៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏រីករាយនិងថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត និងលោកជំទាវ ព្រមទាំងបុត្រាបុត្រី និងចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូណ៌ និងទទួលបាននូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា ។

ថ្ងៃ ១២ ១០ ១០ ១០